**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
***Nation - Religion - King***

**ក្រសួងពាណិជ្ជកម្ម**
*Ministry of Commerce*

លេខ ១៥៥៣ ព.ណ.ភ.ស.រ

ភ្នំពេញ, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៧

**<u>ជម្រាបមក</u>**

**លោក/លោកស្រីប្រធានក្រុមហ៊ុន អិន ស៊ី អិច**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលម៉ូតូ និងគ្រឿងបន្លាស់ម៉ាក "AIR BLADE", និង "icon" ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **អិន ស៊ី អិច**។

**យោង:**
- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៧
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន HONDA MOTOR CO., LTD ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៧
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/២៨៧៦៧/០៨ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៨
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/២៨៧៦៨/០៨ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៨។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលម៉ូតូ និងគ្រឿងបន្លាស់ពាក់ម៉ាកខាងលើក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **អិន ស៊ី អិច** ដែលទទួលបានពីក្រុមហ៊ុន HONDA MOTOR CO., LTD ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ ។

លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ មានសុពលភាពត្រឹមថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៧ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន HONDA MOTOR CO., LTD ដែលជាម្ចាស់ម៉ាក ។

ចាប់ពីរយៈពេល ៩០(កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ អ្នកទទួលសិទ្ធិស្របច្បាប់ មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងចំពោះទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្ត ជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**<u>ចម្លងជូន:</u>**
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- ឯកសារ - កាលប្បវត្តិ

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**